នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
ភាគីដាក់ឯកសារ៖ លោក ខៀវ សំផន
ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ បារាំង
កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២០ ខែមិនា ឆ្នាំ២០២៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Mar-2023, 16:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖
ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

សេចក្ដីសង្កេតបន្ទាប់ពីផ្ទេរលោក ខៀវ សំផន ទៅឃុំឃាំងនៅពន្ធនាគារខេត្តកណ្ដាល
ចម្លើយតបរបស់រដ្ឋបាលតុលាការ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣

---

ដាក់ដោយ៖
**មេធាវីការពារក្ដីលោក ខៀវ សំផន**
មេធាវី គង់ សំអុន
មេធាវី Anta GUISSÉ

ដាក់ជូន៖
**អង្គជំនុំជម្រះតុលាការកំពូល៖**
ចៅក្រម គង់ ស្រ៊ឹម
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរិវឌ្ឍ
ចៅក្រម Florence Ndepele MWACHANDE-MUMBA
ក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Phillip RAPOZA
ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Fergal GAYNOR

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") បានចេញសេចក្តីថ្លែងសម្អាងហេតុពេញលេញនៅក្នុងសាលដីកានៃសំណុំរឿង០០២/០២ ("សាលដីកា") ដែលនៅក្នុងនោះ តុលាការកំពូលបានអះអាងបញ្ជាក់ភាគច្រើនទៅលើការផ្តន្ទាទោសលោកខៀវ សំផន តាមរយៈសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលចេញនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។[1]

២. នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ សហព្រះរាជអាជ្ញាបានស្នើសុំជាផ្លូវការឱ្យផ្ទេរលោក ខៀវ សំផន ទៅកាន់ពន្ធនាគារខេត្តកណ្តាល។ ការផ្ទេរនេះធ្វើឡើងនៅព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣។

៣. បន្ទាប់ពីការស្នើរបស់តុលាការកំពូលសុំឱ្យផ្តល់ព័ត៌មានអំពីក្របខ័ណ្ឌដែលបានព្រាងទុកនៅក្នុងកិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការងារនៅសេសសល់ របស់ អ.វ.ត.ក[2] រដ្ឋបាលនៃអង្គជំនុំជម្រះក៏បានដាក់ការឆ្លើយតបវិញ ដោយបានជូនដំណឹងនៅថ្ងៃទី២៣ ខែកុម្ភៈកន្លងទៅនេះ។[3]

៤. តាមរយៈសំណេរទាំងនេះ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") មានបំណងជូនដំណឹងដល់តុលាការកំពូលអំពីការលំបាកដែលលោក ខៀវ សំផន និងមេធាវីរបស់លោកជួបប្រទះ ហើយសូមធ្វើការសង្កេត និងសម្តែងពីកង្វល់របស់យើងខ្ញុំ បន្ទាប់ពីទទួលបានការឆ្លើយតបរបស់រដ្ឋបាលនៃអង្គជំនុំជម្រះ ("ចម្លើយតប")។

- ការលំបាកក្នុងពេលឃុំខ្លួនក្នុងពន្ធនាគារខេត្តកណ្តាល

៥. ក្រុមមេធាវីការពារក្តីបានធូរស្រាលក្នុងចិត្ត ដោយសារមានការបន្តការព្យាបាលលោក ខៀវ សំផន និងការតាមដានជំងឺដោយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ នៅដំណាក់កាលនេះ មិនមានឧប្បត្តិហេតុណាមួយដែលត្រូវរាយការណ៍ក្នុងការតាមដានផ្នែកវេជ្ជសាស្ត្រនោះឡើយ។ ក្រុមមេធាវីការពារក្តីក៏ស្វាគមន៍ផងដែរចំពោះការអះអាងរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) អំពីចេតនារបស់ខ្លួនក្នុងការបន្តទៅជួបលោក ខៀវ សំផន ជាទៀងទាត់ ដើម្បីវាយតម្លៃលក្ខខណ្ឌនៃការឃុំខ្លួនរបស់លោក។

៦. បន្ទាប់ពីបានរំឭកឡើងវិញអំពីចំណុចវិជ្ជមានទាំងនេះ វានៅតែមានការលំបាកទាក់ទងនឹងលទ្ធភាពរបស់លោក ខៀវ សំផន

---

[1] សេចក្តីសង្ខេបនៃសាលក្រមដែលបានថ្លែងក្នុងសវនាការនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/529.1** ។ សេចក្តីថ្លែងសម្អាងហេតុពេញលេញនៅក្នុងសាលក្រមនៃសំណុំរឿង០០២/០២ ដែលជូនដំណឹងដល់ភាគី នៅថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១៩ ឯកសារ **E465**។

[2] *Addendum to the Agreement between the Royal Government of Cambodia and the United Nations concerning the persecution under Cambodian law of crimes committed during the period of Democratic Kampuchea on the Transitional Arrangements and the Completion of Work of the Extraordinary Chambers*, Août 2021 ("l'Addendum à l'Accord"). Article 2-1 (*Residual Functions*)

[3] *Office of Administration response to the Supreme Court Chamber's request for information regarding the supervision of KHIEU Samphân's sentence*, **F77/1/2** ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ជូនដំណឹងដល់ភាគី នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣។

ក្នុងការយល់ដឹងពេញលេញអំពីសាលដីកាដោយទទួលបានអត្ថប្រយោជន៍ពីជំនួយពីមេធាវីប្រឹក្សារបស់លោក។ ជាក់ស្តែង ពន្ធនាគារខេត្តកណ្តាលមិនអនុញ្ញាតឲ្យលោក ខៀវ សំផន ប្រើកុំព្យូទ័រយួរដៃ ដែលលោកប្រើប្រាស់មិនត្រឹមតែដើម្បីអានសាលដីកាក្នុងលក្ខខណ្ឌអនុគ្រោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចយោងទៅលើឯកសារ និងសំណេរទាំងអស់ដែលបានលើកឡើងនៅក្នុងលេខយោងនៃសាលដីកាផងដែរ។

៧. គួររំឭកនៅទីនេះថា លោក ខៀវ សំផន នៅសល់តែភ្នែកតែមួយចំហៀងប៉ុណ្ណោះដែលនៅដំណើរការល្អ ហើយលោកអាចអានឯកសារធម្មតាបាន លុះត្រាមានជំនួយពីកែវពង្រីកប៉ុណ្ណោះ ហើយអានបានយ៉ាងលំបាក។ ជាច្រើនឆ្នាំមកនេះ កុំព្យូទ័រយួរដៃដែលដាក់ឱ្យលោកប្រើនោះ គឺជាឧបករណ៍តែមួយគត់ដែលអនុញ្ញាតឱ្យលោកអាន និងសរសេរបានត្រឹមត្រូវ ពីព្រោះលោកអាចពង្រីកអក្សរឱ្យធំៗបាន។ សាលដីកាមានច្រើនជាង ១០០០ ទំព័រ និងមានលេខយោងដល់ទៅ ៥៨២៨ ។ ដោយសារស្ថានភាពមិនល្អនៃចក្ខុប្រសាទរបស់លោក និងដោយគ្មានលទ្ធភាពប្រើប្រាស់កុំព្យូទ័រផងនោះ ស្ថានការណ៍នេះ មិនអាចឱ្យលោក ខៀវ សំផន ទ្រាំទ្របានឡើយ។

៨. បន្ថែមលើនេះ មធ្យោបាយតែមួយគត់ដើម្បីឆ្លើយឆ្លងជាមួយមេធាវីអន្តរជាតិរបស់លោក ដែលលោកមានទំនាក់ទំនងជាភាសាបារាំង គឺការផ្ញើ និងទទួលការឆ្លើយឆ្លងការវាយបញ្ចូលឯកសារអេឡិចត្រូនិកតាមរយៈលោកមេធាវីជាតិ។ មានន័យថា ចាប់តាំងពីការផ្ទេរលោក ខៀវ សំផនមក លោកមិនអាចទំនាក់ទំនងដោយផ្ទាល់ និងសម្ងាត់ជាមួយមេធាវីអន្តរជាតិរបស់លោកបានទេ។

៩. នេះក៏មានន័យផងដែរថា ចាប់តាំងពីការបកប្រែសាលដីកាទៅជាភាសាបារាំងមក មេធាវីអន្តរជាតិរូបនេះមិនអាចផ្តល់ការពន្យល់ដល់លោកថាលោកមានសិទ្ធិរង់ចាំដោយស្របច្បាប់នូវសម្អាងហេតុនៃសេចក្តីសម្រេចមួយដែលនាំឱ្យមានការកាត់ទោសលោកឱ្យជាប់ពន្ធនាគារអស់មួយជីវិតនោះទេ។ ដូច្នេះ មេធាវីការពារក្តីឲ្យលោក ខៀវ សំផន មិនមានតួនាទីផ្តល់យោបល់ពេញលេញ និងគ្រប់គ្រាន់ជូនលោក ហើយក៏មិនអាចប្រមូលការសង្កេតរបស់លោកបានទាំងស្រុង សម្រាប់បណ្តឹងសើរើ ដែលមានចែងក្នុងវិធាន ១១២ នៃវិធានផ្ទៃក្នុងនោះបានឡើយ។

១០. ដើម្បីឱ្យមានតម្លាភាពជាមួយតុលាការកំពូល មេធាវីការពារក្តីយល់ថាវាមានប្រយោជន៍ក្នុងការចង្អុលបង្ហាញថារដ្ឋបាលតុលាការបានផ្ញើអ៊ីមែលទៅសហមេធាវីទាំងពីរកាលពីថ្ងៃទី៣ ខែកុម្ភៈកន្លងទៅនេះ ដែលមានចំណងជើងថា "ការផុតកំណត់នៃសេវាផ្លូវច្បាប់"[4] ដែលរៀបរាប់យ៉ាងច្បាស់អំពីដែនកំណត់នៃលទ្ធភាពផ្តល់ប្រាក់បំណាច់ដល់មេធាវីការពារក្តី។ ការបំពេញការងារឆាប់រហ័សដូចបានរៀបរាប់ខាងលើ ទាក់ទងនឹងការជួយលោក ខៀវ សំផន ឱ្យយល់ច្បាស់ពីសម្អាងហេតុនៃសាលដីកា

[4] សារអេឡិកត្រូនិក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៣ របស់លោក គង់ សុគន្ធ ដែលមានចំណងជើងថា *« Expiration of Legal services »* ភ្ជាប់ជាមួយនឹងឯកសារ *« DSS's letter to Co-lawyers for Khieu Samphan »* ដែលចង្អុលបង្ហាញជាពិសេស : *« 3. According ti teh Legal Services Contract, the purpose of the contract has been fulfilled. « Proceedings » as defined in section 2.6 have completed, and the contract has expired without any advance notice per section 4.1 '. Howerver in keepingthe spirit of the UN-RGC Addendum, any legal representation by Defence counsel as and when it is required during the period of residual functions shall be on the modaity of the Addendum. Remunaration will be considered on a case-by-case basis and only after have Defencefilings been actioned by the appropriate chamber on their merits. Remunaration may on those circumstances be in accordance with the Legal Services Contract on a time sheet basis. »*

ដូច្នេះកើតចេញពីបំណងប្រាថ្នាតែមួយគត់របស់សហមេធាវីការពារក្តី ដើម្បីបំពេញកាតព្វកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈសម្រាប់កូនក្តី។

១១. ក្នុងន័យនេះ វាក៏សំខាន់ផងដែរក្នុងការគិតគូរដល់ស្ថានភាពពិសេសរបស់សហមេធាវីជាតិ គឺលោក គង់ សំអុន ដែលជាមនុស្សតែម្នាក់គត់ដែលអាចប្រឹក្សាដោយផ្ទាល់ជាមួយលោក ខៀវ សំផន។ ការទៅសួរសុខទុក្ខ តែមួយលើកគត់ដែលគាត់អាចធ្វើបាន បានប្រព្រឹត្តទៅយ៉ាងលំបាក។ ដោយអនុះសារចង់ឃើញលក្ខខណ្ឌនៃការឃុំខ្លួនលោក ខៀវ សំផន សហមេធាវីជាតិត្រូវធ្វើដំណើររយៈពេល ២ម៉ោង ដោយសារតែពន្ធនាគារខេត្តកណ្តាលនៅឆ្ងាយពីផ្ទះលោក។ លើសពីនេះទៀត លោកត្រូវរង់ចាំបន្ថែមពីរម៉ោងទៀត ដើម្បីទទួលបានការអនុញ្ញាតជួបកូនក្តីសម្រាប់ការសម្ភាសន៍តែត្រឹមថិរវេលាមួយម៉ោងប៉ុណ្ណោះ។

១២. អាស្រ័យដោយលក្ខខណ្ឌទាំងនេះ យើងខ្ញុំស្នើសុំរដ្ឋបាល ឬតុលាការកំពូលមេត្តាកំណត់លក្ខខណ្ឌណាមួយ ដែលបញ្ហាទាំងនេះអាចត្រូវបានដោះស្រាយ ពោលគឺ៖
១. អនុញ្ញាតឱ្យលោក ខៀវ សំផន ប្រើប្រាស់កុំព្យូទ័រយួរដៃរបស់លោក។
២. ដាក់បញ្ចូលនីតិវិធីអនុញ្ញាតឱ្យលោក គង់ សំអុន ចូលជួបលោក ខៀវ សំផន តាមលក្ខខណ្ឌដ៏ល្អប្រសើរ។

ការព្រួយបារម្ភនៃមេធាវីការពារក្តី តាមរយៈការឆ្លើយតបរបស់រដ្ឋបាលតុលាការ

១៣. ប្រឈមនឹងការលំបាកដូចបានជម្រាបជូនខាងលើ សំណួរនៅតែចោទឡើងជានិច្ចថាតើស្ថាប័នសមស្របមួយណាដែលទទួលបន្ទុកក្នុងការដោះស្រាយបញ្ហាទាំងនោះ។ បន្ទាប់ពីអានចម្លើយតប មេធាវីការពារក្តីមានការងឿងឆ្ងល់អំពីការចូលរួមរបស់រដ្ឋបាលតុលាការ។ ពីព្រោះថា ម៉្យាង រដ្ឋបាលលើកឡើងថា មិនមានយន្តការដែលនៅសេសសល់ដូចយុត្តាធិការអន្តរជាតិផ្សេងៗទៀតនោះទេ ហើយថា៖ *"article 2(1) clarifies the scope of the Extraordinary Chambers's operations following the completion of judicial proceedings within its **existing** framework and organisation »*[5]។ ម៉្យាងវិញទៀត ការឆ្លើយតបហាក់ដូចជាចង់និយាយថា "ក្របខ័ណ្ឌ" អាចជាការិយាល័យរដ្ឋបាលដោយខ្លួនឯង ដោយបញ្ជាក់ពីវត្តមាននៃ "មន្ត្រីដាច់ដោយឡែក" ដែលបង្ហាញថាគាត់នឹងក្លាយជាបុគ្គលទំនាក់ទំនងសម្រាប់បុគ្គលិកតុលាការទាំងអស់ អង្គជំនុំជម្រះ និងភាគីពាក់ព័ន្ធ។[6]

១៤. ម៉្យាង តាមទស្សនៈច្បាប់ និងនីតិវិធីដ៏តឹងរ៉ឹង នៅក្នុងចម្លើយតប មិនមានបញ្ជាក់ទេថាតើតុលាការកំពូលមានសិទ្ធិអំណាចអ្វី ដើម្បីធានាថា លក្ខខណ្ឌនៃការឃុំខ្លួនលោក ខៀវ សំផន គោរពតាមស្តង់ដារអន្តរជាតិ ហើយតើតុលាការកំពូលប្រើប្រាស់របៀបអនុវត្តសិទ្ធិអំណាចនេះតាមបែបណាដែរ។ តើការសម្រេចរបស់តុលាការកំពូលនឹងមានលក្ខណៈយ៉ាងណា ប្រសិនបើតុលាការត្រូវចេញសេចក្តីសម្រេចនោះ នៅពេលអនាគត ? ក្នុងករណីមានបញ្ហាធ្ងន់ធ្ងរ (បញ្ហាកុំព្យូទ័ររបស់លោក ខៀវ សំផន គឺជាបញ្ហាមួយក្នុងចំណោមបញ្ហានោះ) តើមានអំណាច និងមធ្យោបាយអ្វីខ្លះ សម្រាប់តុលាការកំពូល និងមន្ត្រីទំនាក់ទំនងយកទៅអនុវត្ត? មាត្រាទី២ នៃកិច្ចព្រមព្រៀងបន្ថែម មិនអនុញ្ញាតឱ្យគេកំណត់រឿងនេះបានឡើយ។ វត្តមានរបស់មន្ត្រីទំនាក់ទំនងក៏មិនបំភ្លឺស្ថានភាពក្នុងករណីមានមុខតំណែងផ្សេងគ្នារវាងអាជ្ញាធរពន្ធនាគារជាតិ និង អ.វ.ត.ក នោះដែរ (ទោះបីជាស្ថាប័នមានសមត្ថកិច្ចបែបណាក្តី)។

---

[5] ចម្លើយតប ឯកសារ **F77/1/2** កថាខណ្ឌទី៤ ពាក្យត្រូវបានគូសពីក្រោម នៅក្នុងអត្ថបទដើមនៃចម្លើយតប។
[6] ចម្លើយតប ឯកសារ **F77/1/2** កថាខណ្ឌទី៥។

១៥. ម្យ៉ាងវិញទៀត តាមទស្សនៈជាក់ស្តែង មេធាវីការពារក្តីក៏មិនដឹងច្បាស់ថាត្រូវអនុវត្តតាមនីតិវិធីបែបណាដែរ ហើយមិនទាន់យល់ច្បាស់ថា តើតុលាការកំពូលនឹងនៅតែស្ថិតក្នុងទម្រង់បច្ចុប្បន្នរបស់ខ្លួន ហើយមិនដឹងថាតើមេធាវីការពារក្តីត្រូវដាក់សំណើររបស់ខ្លួននៅថ្ងៃមុខទៅនរណាដើម្បីឲ្យជួយដោះស្រាយ។ មេធាវីការពារក្តីមិនដឹងថានៅពេលណាដែលខ្លួនបញ្ចប់ការធ្វើសំណើជាលាយលក្ខណ៍អក្សរប្រសិនបើសំណើទាំងនោះត្រូវបានទទួលយកក្នុងទម្រង់នៃរចនាសម្ព័ន្ធបច្ចុប្បន្ន។

១៦. សរុបសេចក្តីមក មេធាវីការពារក្តីសូមស្នើសុំការបំភ្លឺជាក់លាក់អំពីរបៀបនៃការធ្វើទៅថ្ងៃអនាគត។ ចង់ដឹងថាតើខ្លួនត្រូវដាក់ទៅនរណានូវសំណើទាំងឡាយដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់ការពារសិទ្ធិរបស់ទណ្ឌិត ខៀវ សំផន ដែលនៅខណៈនេះកំពុងមានភាពចាំបាច់ក្នុងការស្នើសុំទៅថៅក្រមណាម្នាក់។

ធ្វើនៅទីក្រុងប៉ារីស និងនៅទីក្រុងភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣

| | | |
|---|---|---|
| មេធាវី គង់ សំអុន | ទីក្រុងភ្នំពេញ | |
| មេធាវី **Anta GUISSÉ** | ទីក្រុងប៉ារីស | |